រាជរដ្ឋាភិបាលកម្ពុជា

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

អគ្គលេខាធិការដ្ឋាន

លេខៈ ០៦៣/១៣ [illegible] អ.ជ.ប.គ.ញ


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ មិថុនា ឆ្នាំ២០១៣ និងទិសដៅការងារ ខែ កក្កដា ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/៦/២០១៣ ដល់ ថ្ងៃទី ៣០/៦/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តន៍តាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្តន៍ "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុងខែមិថុនា ឆ្នាំ២០១៣ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន និង រាជធានី-ខេត្តចំនួន ១១ គឺ រាជធានីភ្នំពេញ, ខេត្តកណ្តាល, តាកែវ, កំពង់ស្ពឺ, កំពង់ឆ្នាំង, កំពង់ចាម, ព្រៃវែង, រតនគិរី, កំពត, បាត់ដំបង, បន្ទាយមានជ័យ និង ខេត្តក្រចេះ ដែលបានរាយការណ៍ពីលទ្ធផលនៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបក្នុងខែមិថុនានេះ បានកត់សំគាល់ឃើញ នៅទិសខេត្តជាប់ព្រំដែនថៃ សមត្ថកិច្ចបង្ក្រាបបាន ៥ ករណី, ទិសជាប់ព្រំដែនវៀតណាម បង្ក្រាបបាន ១២ ករណី និងខេត្តក្នុងផ្ទៃប្រទេស ដូចមានរាយឈ្មោះខាងលើ បង្ក្រាបបាន ៣២ ករណី ។

គួរកត់សំគាល់ផងដែរ នៅក្នុងខែមិថុនានេះ មានមួយករណីមេតំហ្វេតាមីន (ICE) ត្រូវបានបណ្តាញនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ ធ្វើសកម្មភាពដឹកជញ្ជូនពីប្រទេសនីហ្សេរីយ៉ា ចូលមកកម្ពុជាតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដែលមន្ទីរប្រឆាំងគ្រឿងញៀន បានសហការជាមួយសមត្ថកិច្ចចម្រុះនៅទីនោះ បង្ក្រាបទាន់ពេលវេលា ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ , Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. អំពីការដឹកនាំនៃស្ថាប័នកំពូលរបស់ថ្នាក់ជាតិ

- **រាជរដ្ឋាភិបាលកម្ពុជា** ក្រោមការដឹកនាំរបស់សម្តេច នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងសារដាស់តឿន ក្រើនរំលឹក ផ្ញើជូនដល់បងប្អូនជនរួមជាតិ ជាពិសេសយុវវ័យឱ្យចៀសឆ្ងាយពីគ្រឿងញៀននៅក្នុង :
  - ឱកាសខួបលើកទី៦៤ ទិវាកុមារអន្តរជាតិ ១ មិថុនា និងខួបលើកទី១២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២ មិថុនា (ខ្លឹមសារចំណុចទី៦[៩]) ។
  - ឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១៣ ។
- **កាកបាទក្រហមកម្ពុជា** ក្រោមការដឹកនាំរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ បានចុះសួរសុខទុក្ខ និងនាំយកអំណោយសប្បុរសធម៌កាកបាទក្រហម ទៅចែកជូនប្រជាពលរដ្ឋ នៅស្រុកកោះធំ ខេត្តកណ្តាល និងបានដាស់តឿនក្រើនរំលឹក ផ្តល់ដំបូន្មានល្អៗ ដល់ក្មួយៗយុវវ័យពាក់ព័ន្ធទៅនឹងច្បាប់ចរាចរណ៍, បញ្ហាគ្រឿងញៀន និង ជំងឺអេដស៍ ។

### ២. អំពីការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានដឹកនាំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "២៦ មិថុនា ២០១៣" នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ និងបានណែនាំដល់គ្រប់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ឱ្យរៀបចំប្រារព្ធទិវានេះ នៅក្នុងរាជធានី-ខេត្តរបស់ខ្លួន ។
- បានប្រគល់ភារកិច្ចជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងតំណាង ទៅចូលរួមជាអធិបតី នៅក្នុងទិវា "២៦ មិថុនា ២០១៣" នៅខេត្តគោលដៅចំនួន ៦ គឺ ខេត្តបាត់ដំបង, ខេត្តកំពង់ចាម, ខេត្តព្រះសីហនុ, ខេត្តក្រចេះ, ខេត្តស្ទឹងត្រែង និង ខេត្តសៀមរាប ។
- បានអនុញ្ញាតជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមជាគណៈអធិបតី ក្នុងឱកាសខួបលើកទី៦៤ ទិវាកុមារអន្តរជាតិ១មិថុនា និងខួបលើកទី១២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២មិថុនា នៅវិទ្យាល័យឥន្ទ្រទេវី (៣១/៥/២០១៣) ។
- បានអនុញ្ញាតឱ្យតំណាងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមក្នុងកិច្ចប្រជុំប្រកាសផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់ អត្រាភាពក្រីក្រនៅកម្ពុជា ដោយផ្អែកលើខ្សែបន្ទាត់ភាពក្រីក្រថ្មី ដែលត្រូវបានកែសម្រួល និងឯកសារស្តីពីការបញ្ចូលទស្សនទានប្រជាសាស្ត្រទៅក្នុងការអភិវឌ្ឍនៅកម្ពុជា (តាមការអញ្ជើញរបស់ក្រសួងផែនការ) ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិ ក៏ដូចជាផែន

---

[៩] **ចំណុចទី៦** ត្រូវបន្តជំរុញការអនុវត្តគោលនយោបាយ ភូមិ-ឃុំមានសុវត្ថិភាព សំដៅរួមចំណែកទប់ស្កាត់បញ្ហាគ្រឿងញៀន អនីតិជនទំនាស់នឹងច្បាប់ ឬក្មេងទំនើង ព្រមទាំងត្រូវបន្តអនុវត្តកម្មវិធីយុត្តិធម៌អនីតិជនតាមពន្ធនាគារ ផ្តល់នូវការការពារចំពោះនីតិជនស្របតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ទន្ទឹមនេះ ចលនាយុវជនកាកបាទក្រហម និងកាយឬទ្ធិកម្ពុជាត្រូវបង្កើនឱ្យបានសកម្មខ្លាំងក្លាថែមទៀតក្នុងការអប់រំយុវជននិងកុមារអំពីសីលធម៌ សុជីវធម៌ ឱ្យចេញឆ្ងាយពីការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹងគ្រប់ប្រភេទ ដែលជាការងារមួយជួយលើកតម្លៃ និង ឧត្តមប្រយោជន៍នៃសង្គមជាតិរបស់យើង ។

ការអនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពីខែឧសភា ឆ្នាំ២០១៣ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

## *ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាលមួយចំនួនទៀត ជាអាទិ៍ អគ្គិសនីកម្ពុជា បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំ ថ្ងៃ សប្តាហ៍ និង ខែ, ការអប់រំតាមសហគមន៍, ការបណ្តុះបណ្តាលធនធានមនុស្ស រួមទាំងការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "២៦ មិថុនា ២០១៣"[2] ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងតារាងឧសម្ព័ន្ធទី១។ ដោយឡែក :**

**១- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ** បានអញ្ជើញជាគណៈអធិបតី នៅក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន "២៦ មិថុនា ២០១៣" នៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២០ខែមិថុនាឆ្នាំ២០១៣ ។

**២- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :**

- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន បានអញ្ជើញជាអធិបតីនៅក្នុងទិវាកុមារអន្តរជាតិលើក
- ទី៦៤ ដែលប្រារព្ធធ្វើនៅវិទ្យាល័យឥន្ទ្រទេវី មានសិស្សានុសិស្ស តំណាងសហគមន៍ តំណាងមាតាបិតា ចូលរួមសរុបប្រមាណ <u>៥០០</u> នាក់ ។
- បានចូលរួមតាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍ និងសន្តិភាព ដើម្បីពិភាក្សាលើប្រធានបទស្តីពី "ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង និងសុវត្ថិភាពចរាចរណ៍" កាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ដែលអ្នកពាក់ព័ន្ធចូលរួម <u>២០</u> នាក់ (ដើម្បីក្តាប់បានខ្លឹមសារពាក់ព័ន្ធបញ្ហាគ្រឿងញៀន) ។
- បានចូលរួមធ្វើបទឧទ្ទេសនាមស្តីពីគ្រឿងញៀន ដល់និស្សិត ចំនួន <u>៣០០</u> នាក់ នៃសាកលវិទ្យាល័យចម្រើនពហុបច្ចេកវិទ្យា កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ។
- បានចូលរួមក្នុងសិក្ខាសាលា ស្តីពី ការចូលរួមទប់ស្កាត់បញ្ហាគ្រឿងស្រវឹង តាមការអញ្ជើញរបស់សមាគមយុវជនខ្មែរ ក្នុងគោលបំណងផ្សព្វផ្សាយពីសកម្មភាពការងាររបស់គម្រោង ការអប់រំបង្ការការប្រើប្រាស់គ្រឿងញៀន និងគ្រឿងស្រវឹងដល់អ្នកពាក់ព័ន្ធ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ នៅវិទ្យាល័យសម្តេច ហ៊ុន សែន ភ្នំពេញថ្មី ។
- បានចូលរួមសិក្ខាសាលាបង្ហាញលទ្ធផលអង្កេតដំបូងលើការអនុវត្តកម្មវិធីការអប់រំបំណិនជីវិត ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សម្រាប់យុវវ័យក្នុង និងក្រៅសាលារៀន កាលពីថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៣ តាមការអញ្ជើញរបស់ក្រសួងអប់រំ យុវជន និងកីឡា (ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន) ។
- បានចូលរួមក្នុងកម្មវិធី "បាយ័នថ្ងៃនេះ" របស់ទូរទស្សន៍បាយ័ន ក្រោមប្រធានបទ (លទ្ធផលក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រឿងញៀន) កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៣ ។

[2] នៅមានខេត្តមួយចំនួនធំមិនទាន់ផ្ញើលទ្ធផលនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១៣ មកអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហគមន៍ និងការងារបណ្ដុះបណ្ដាលធនធានជនបង្គោល ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង-ស្ថាប័នដទៃទៀត ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមទាំងការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ១០ គឺ ខេត្តក្រចេះ ព្រះវិហារ បាត់ដំបង តាកែវ កំពង់ស្ពឺ ស្វាយរៀង កំពង់ចាម ប៉ៃលិន សៀមរាប និង ខេត្តបន្ទាយមានជ័យ នៅក្នុងខែមេសា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួមសរុប ***១១៩.១៨១ នាក់*** លើ ១១៣.២៧៨ នាក់ នៃខែឧសភា **ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១** ។

## ***ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ក្នុងខែមិថុនា ឆ្នាំ២០១៣ នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### ***ខ.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន***

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន ***៤៩*** ករណី លើ ៥៩ ករណី នៃខែ ឧសភា ឆ្នាំ ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន ***៩៤*** នាក់ លើ ១២០ នាក់ នៃខែ ឧសភា ឆ្នាំ២០១៣
- **ចាប់តាមដីកា មាន** ២ ដីកា = ២ នាក់ ( ប្រុស) ជនជាតិខ្មែរ

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **៩៤** នាក់ ខាងលើ មានប្រុស ៧៥ នាក់ ស្រី ១៩ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ៨៩ នាក់ ( ស្រី ១៧ នាក់), **វៀតណាម** ៤ នាក់ ( ស្រី ២ នាក់), **នីហ្សេរីយ៉ា** ១ នាក់ ( ប្រុស), ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

- **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន
  - មេតំហ្វេតាមីន (WY) ៩៥,៨៤ ក្រាម
  - មេតំហ្វេតាមីនក្រាមម្សៅ (Ice) ២.៨២១,៨ ក្រាម
  - អ៊ិចស្តាស៊ី ១០,០២ ក្រាម និងសារធាតុផ្សេងៗទៀត **ដូចមានក្នុងតារាង ឧបសម្ព័ន្ធទី២**
- **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក** រួមមាន :
  ម៉ូតូ ១៧ គ្រឿង, ប្រាក់កម្ពុជា ៣៣៩.១០០ រៀល, ប្រាក់អាមេរិក ២.០៦៥ ដុល្លារ

### ***ខ.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ***

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសុខាភិបាល ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ, វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធប្រសាទ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុង ខែមិថុនា ឆ្នាំ២០១៣ មានដូចខាងក្រោម :

- សារធាតុគីមីគិតជា គីឡូក្រាម ចំនួន ១.៤៦២.៥៦០ Kgs និង ១៤០ លីត្រ និង ១០ អំពូល
- វត្ថុធាតុដើម និង ឱសថប៉ះពាល់ប្រព័ន្ធប្រសាទ ចំនួន ៥០៥ g **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២**

### ខ.៣. ការងារកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តច្បាប់នានា នៅក្នុងខែមិថុនានេះ សរុបបានចំនួន ១១ ករណី = ៥៦ សំណាក (**សំណាកអវិជ្ជមានសារធាតុញៀន** ៣ សំណាក = ១ % និង សំណាក**វិជ្ជមានសារធាតុញៀន** ៥៣ សំណាក = ៩៩ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ១៩ សំណាក = ៣៦ % -មេតំហ្វេតាមីនគ្រាប់ ៣ សំណាក = ៦ %

-កូកាអ៊ីន ១ សំណាក = ១ % -ជ័រអាភៀន ៧ សំណាក = ១៣ %

-ហេរ៉ូអ៊ីន ២៣ សំណាក = ៤៣ % **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២**

ក្រៅពីការងារកោសលវិច័យលើសំណាកវត្ថុតាងសង្ស័យជាគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានទទួលនូវ ទី១) ម៉ាកគ្វីតេស្ត ចំនួន ១.០០០ តេស្ត, ទី២) កូកាអ៊ីនតេស្ត ចំនួន ១៥០ តេស្ត, ទី៣) កេតាមីនតេស្ត ចំនួន ២០០ តេស្ត, ទី៤) មេតំហ្វេតាមីនតេស្តទឹកនោម ចំនួន ២.០០០ តេស្ត, ទី៥) ហេរ៉ូអ៊ីនតេស្តទឹកនោម ចំនួន ៥០០ តេស្ត ពីក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ ។

## គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់ទីជ្រកវិញ និងសមាហរណកម្ម

### គ.១. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់

- បានចូលរួមកិច្ចប្រជុំក្រុមការងាររួម រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការងារមេរោគអេដស៍ និងជំងឺអេដស៍ កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ (ដើម្បីក្តាប់បានបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន) ។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលបឋមនៃការអង្កេតជាតិលើការចំណាយប្រយុទ្ធនឹងជំងឺអេដស៍លើកទី៤ ឆ្នាំ ២០១១-២០១២ កាលពីថ្ងៃទី៣១/៥/២០១៣ នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ដែលមានអ្នកចូលរួម **៦៥** រូប (ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន) ។
- បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនូវវឌ្ឍនភាពឆ្ពោះទៅសម្រេចបាននូវគោលដៅ និងការប្តេជ្ញាចិត្ត ចំពោះសេចក្តីថ្លែងការណ៍គោលនយោបាយឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានអនុម័ត ឆ្នាំ២០១១ នៅក្នុងកិច្ចប្រជុំកម្រិតខ្ពស់នៃមហាសន្និបាតអង្គការសហប្រជាជាតិ នៅសណ្ឋាគារសាន់វេ ថ្ងៃទី ០៤/៦/២០១៣ (ដើម្បីក្តាប់បានពីបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន) ។
- បានចាត់មន្ត្រី ១ រូប ចូលជាសមាជិកក្រុមការងារបច្ចេកទេស ដើម្បីតាមដានការអនុវត្តយុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ ថែទាំ ព្យាបាលបន្តដល់ក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ តាមការស្នើសុំរបស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (ដើម្បីក្តាប់បានពីការឆ្លងមេរោគអេដស៍ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន) ។
- បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសជាតិតាមដាន និងវាយតម្លៃយុទ្ធសាស្ត្រទី៦ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ កាលពីថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣ (ដើម្បីក្តាប់បានពីបញ្ហាដែលពាក់ព័ន្ធនឹងគ្រឿងញៀន) ។

- បានចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំរវាងអង្គការខាន់ណា ជាមួយអង្គការដៃគូ កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលមានគោលបំណង ១) ផ្សព្វផ្សាយនូវលទ្ធផលបឋមនៃការអនុវត្តផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ (២០១១-២០១៥) របស់អង្គការខាន់ណា ២) ធ្វើបច្ចុប្បន្នភាពនិងណែនាំនូវការងារបច្ចេកទេសថ្មីៗសម្រាប់អនុវត្តគាំទ្រយុទ្ធសាស្ត្រកម្ពុជា បីចុចសូន្យ របស់ក្រសួងសុខាភិបាល ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ ៣) ណែនាំនូវគំនិតផ្តួចផ្តើមថ្មីៗក្នុងការគ្រប់គ្រង និងអនុវត្តគម្រោងដល់អង្គការដៃគូ (ដើម្បីក្តាប់បានបញ្ហាពាក់ព័ន្ធគ្រឿងញៀន) អ្នកចូលរួម**១៦០**នាក់ ។
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយ និងចាប់ផ្តើមអនុវត្តន៍គម្រោងកម្មវិធីបង្ការមេរោគអេដស៍ និងគ្រឿងញៀន នៅកម្ពុជា ដល់មន្ត្រីនៃអង្គភាព-មន្ទីរពាក់ព័ន្ធចំណុះសាលាខេត្តបាត់ដំបង កាលពីថ្ងៃទី០៤-០៧ ខែ មិថុនា ឆ្នាំ ២០១៣ (មានអ្នកចូលរួមចំនួន **៧០** នាក់) ។

### គ.២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលមុខរបរ និងសមាហរណកម្ម

- បានសម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ ដើម្បីឱ្យតំណាងអង្គការ UNODC ប្រចាំទីក្រុងវីយែន និងក្រុមការងារចុះទៅពិនិត្យការងារព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ នៅខេត្តបន្ទាយមានជ័យ (៣១/៥/២០១៣) ។
- បាននិងកំពុងរៀបចំ ឯកសារគម្រោងជំនួយ ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ដើម្បីផ្ញើជូនទៅស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ។

## ឃ. ការពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់

### ការងារក្នុងប្រទេស

- បានរៀបចំវគ្គបណ្តុះបណ្តាល របស់សាលាបណ្ឌិត្យសភានគរបាលកម្ពុជា លើកទី១ ចំនួន <u>៤០</u> រូប ពីថ្ងៃទី១០-១៤ ខែមិថុនា ឆ្នាំ២០១៣ នៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា (ដីឥដ្ឋ) ។
- បានចូលរួមកិច្ចប្រជុំពិភាក្សាតុមូល លើកទី៣ ស្តីពីការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា កាលពីថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ នៅក្នុងស្ថានីយវិទ្យុស្ត្រីកម្ពុជា ។
- បានពិភាក្សាការងារជាមួយបណ្ឌិត្យសភានគរបាលកម្ពុជា និងនៅសាលានគរបាលភូមិភាគ៥ (ខេត្តកំពង់ស្ពឺ) និង ភូមិភាគ៣ (ខេត្តបាត់ដំបង) ពីថ្ងៃទី ១៨-២២ ខែមិថុនា ឆ្នាំ២០១៣ ។

### ការងារក្រៅប្រទេស

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់អគ្គលេខាធិការ អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីអនុវត្តច្បាប់របស់បណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ សរុបចំនួន ៣៥ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសស៊ើបអង្កេតស្រាវជ្រាវរកគ្រឿងញៀន និងការធ្វើតេស្តទឹកនោម ពីថ្ងៃទី០២-០៧/៦/២០១៣ នៅប្រទេសថៃ ។ មន្ត្រីអនុវត្តច្បាប់ ទាំង ៣៥ រូប បានទទួលវគ្គបណ្តុះបណ្តាលស្តីអំពី :
  - ចំណេះដឹងជាមូលដ្ឋាន ស្តីពីគ្រឿងញៀន និងសារធាតុគីមីផ្សំ
  - ស្ថានភាពគ្រឿងញៀន និងសារធាតុគីមីផ្សំ នៅក្នុងប្រទេសថៃ និង កម្ពុជា

- កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យទំនាក់ទំនងព្រំដែន (BLO)
- បច្ចេកទេសស៊ើបអង្កេត ត្រួតពិនិត្យបទល្មើស ពិសេសបទល្មើសគ្រឿងញៀនឆ្លងកាត់ព្រំដែន

### *ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ*

ខែមិថុនាឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ មានដូចខាងក្រោម :

- បានសម្របសម្រួលជូនមន្ត្រីជាន់ខ្ពស់នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលអន្តរជាតិ ជូនមន្ត្រីអនុវត្តច្បាប់គ្រឿងញៀន ដែលជាសមាជិកប្រទេស (CICA. Conference on Interaction and Confidence Building Measures in Asia)
  ពីថ្ងៃទី១០-២១ ខែមិថុនា ឆ្នាំ២០១៣ នៅប្រទេសថៃ ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋាន ១ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មអន្តរជាតិ នៅទីក្រុងសេអ៊ូល សាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី១៧-២១/៦/២០១៣ ។
- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប និងសម្របសម្រួលជូនមន្ត្រីជំនាញរបស់ក្រសួងសមាជិក អ.ជ.ប.គ.ញ ដែលមានការពាក់ព័ន្ធ ចំនួន ១៤ រូប (សរុប **១៥** រូប) ទៅទទួលវគ្គបណ្តុះបណ្តាល ស្តីពីការត្រួតពិនិត្យសារធាតុគីមីផ្សំ កាលពីថ្ងៃទី២៣ ខែមិថុនា ដល់ ថ្ងៃទី០៧ ខែកក្កដា ឆ្នាំ ២០១៣ នៅខេត្តគុនមិញ ប្រទេសចិន ។
- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប ទៅចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ ADLOMICO លើកទី២៣ កាលពីថ្ងៃទី២៦-២៩/៦/២០១៣ នៅសាធារណរដ្ឋកូរ៉េ ។

***ការងារផ្សេងៗ :***

- បាននិងកំពុងរៀបចំក្រុមបាវកថា សម្រាប់បម្រើឱ្យការងារផ្សព្វផ្សាយច្បាប់ និងការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។
- បានបន្តពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែកក្កដា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តន៍ទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាអប់រំស្តីពី គ្រោះថ្នាក់ដោយសារគ្រឿងញៀន និងជំងឺអេដស៍ និងបញ្ហាប្រឈមរបស់សាកលវិទ្យាល័យ អាស៊ី អឺរ៉ុប នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣ ដែលមានសាស្ត្រាចារ្យ និស្សិត ចូលរួមចំនួន ៤០០ នាក់ ។

១.២. ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាអប់រំស្តីពី ចរាចរគ្រឿងញៀន និងជំងឺអេដស៍ របស់សាកលវិទ្យាល័យ កម្ពុជា

អន្តរជាតិ នាថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៣ ដែលមានសាស្ត្រាចារ្យ និស្សិត ចូលរួម ចំនួន ១៥០ នាក់ ។

១.៣. ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានីភ្នំពេញ ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន និង ស៊ី.អិន.ស៊ី អំពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ( ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣) ។

១.៤. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បណ្តាក្រុមហ៊ុនឯកជន ដើម្បីរៀបចំបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយផលិតផលនានា នៅ តាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៥. បន្តរៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវាត់ពានរង្វាន់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្ថានីយទូរ-ទស្សន៍បាយ័ន និងស្ថានីយទូរទស្សន៍ ល្បីៗមួយចំនួនទៀត ដើម្បីបញ្ជ្រាបការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៦. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីស្រាវជ្រាវស៊ើបអង្កេត និងកំណត់មុខសញ្ញាជាជនបរទេស ដែលសង្ស័យថាជាមេខ្លោងចែកចាយគ្រឿងញៀន តាមការស្នើរបស់ក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៣ ។

២.២. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មន្ទីរប្រឆាំងគ្រឿងញៀន និងស្ថាប័នពាក់ព័ន្ធមួយចំនួនទៀតលើសេចក្តីព្រាងស្តីពី យន្តការនិងប្រព័ន្ធចែករំលែកព័ត៌មានពាក់ព័ន្ធនឹងការត្រួតពិនិត្យសារធាតុគីមី ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. ចាត់បញ្ជូនមន្ត្រីជំនាញ ទៅចូលរួមសន្និសីទអាស៊ាន ឆ្នាំ២០១៣ ស្តីពីផែនទីបង្ហាញផ្លូវឆ្ពោះទៅកាន់ការព្យាបាលអ្នកប្រើគ្រឿងញៀនប្រកបដោយប្រសិទ្ធភាព ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧-១៩/៧/២០១៣ នៅប្រទេសថៃ ។

៣.២. ចាត់បញ្ជូនក្រុមការងារទៅប្រទេសវៀតណាមដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៣.៣. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និងស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៤. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី មូល/ស៊ីរ៉ាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៥. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀនដែលកំពុងសម្រាកព្យាបាល នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៦. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្ត-ភាព ខ្មែរ-សូវៀត ។

៣.៧. បន្តរៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៣.៨. រៀបចំកិច្ចប្រជុំពិភាក្សាជាមួយក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពាក់ព័ន្ធនឹងការជួយគាំទ្ររបស់ភាគីវៀតណាម លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. សហការជាមួយអ្នកសម្របសម្រួលគម្រោង PATROL របស់អង្គការ UNODC ចុះទៅពិនិត្យជាក់ស្តែងសម្ភារៈការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន ៥ កន្លែង នៅច្រកជ្រៃធំ, ចាំយាម, ព្រំ, ដូង និង ប៉ោយប៉ែត ដើម្បីត្រៀមផ្លាស់ប្តូរជូននូវសម្ភារៈថ្មីសម្រាប់ការិយាល័យនេះ ។

៤.២. បន្តរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាព ក្នុងការកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើប៉ាន់គ្រឿងញៀន នៅសាលាបណ្ឌិត្យសភានគរបាលកម្ពុជា (ជីតង់) ។

៤.៣. ត្រៀមកិច្ចសហការសម្របសម្រួលជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ ដែលឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែន ជាពិសេសខ្សែបន្ទាត់ព្រំដែននៃបណ្តាខេត្តនៅភាគពាយ័ព្យ ។

៤.៤. បន្តរៀបចំវគ្គបណ្តុះបណ្តាល ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ (កម្មវិធី CBT) ។

៤.៥. បន្តកិច្ចសហការជាមួយអង្គការជាដៃគូពាក់ព័ន្ធ លើការងារពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ។

៤.៦. បន្តការចុះពិភាក្សាជាមួយសាលានគរបាលភូមិភាគ ១ (ខេត្តស្ទឹងត្រែង) ភូមិភាគ ៣ (ខេត្តបាត់ដំបង) ភូមិភាគ ៥ (ខេត្តកំពង់ស្ពឺ) ។

៤.៧. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១ រូប និងសម្របសម្រួលជូនមន្ត្រីជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ១ រូប ឱ្យទៅចូលរួមសិក្ខាសាលា លើកទី៣ ស្តីពីកិច្ចសហប្រតិបត្តិការ ការអនុវត្តច្បាប់គ្រឿងញៀន សម្រាប់ប្រទេសអាស៊ីបូព៌ា និងអាមេរិកឡាទីន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៩ ខែកក្កដា ដល់ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៣ នៅទីក្រុងបាងកក ប្រទេសថៃ ។

៥.២. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមសិក្ខាសាលាបង្កើតផែនការសកម្មភាពអនុតំបន់ (SAP) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅថ្ងៃទី០៩ដល់ថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ នៅប្រទេសថៃ ។

៥.៣. រៀបចំដំណើរទស្សនកិច្ច សម្រាប់គណៈប្រតិភូនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅទស្សនកិច្ចនៅខេត្តយូណាន ប្រទេសចិន ។

៥.៤. រៀបចំពិធីទទួលសម្ភារៈ ដែលឧបត្ថម្ភដោយគណៈកម្មការធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC) តាមរយៈអង្គការ UNODC ។

ក្រៅពីទិសដៅការងារខាងលើ  អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត  ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- បន្តសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ ដំណើរការរៀបចំបញ្ចូល ផ្ទៀងផ្ទាត់ និងវិភាគទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀន ក្នុងការសិក្សា ការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ និងឥរិយាបថប្រព្រឹត្តប្រឈមគ្រោះថ្នាក់ និងការប៉ាន់ប្រមាណចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅកម្ពុជា ។
- បន្តការរៀបចំក្រុមបាឋកថា ។
- បន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។៚

អគ្គលេខាធិការស្តីទី

ឧត្តមសេនីយ៍ឯក.លី_គឹមឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ